**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៩០/១៥ ក.អ.ជ.ប្រក

ថ្ងៃសុក្រ ១៣ កើត ខែភទ្របទ ឆ្នាំមមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា គ.ស ២០១៥

## ប្រកាស

## ស្តីពី

## ការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** តែងតាំងក្រុមប្រឹក្សាភិបាលនៃគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ហាប់ អ្នម៉ាលី** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. បណ្ឌិត **ភាគ សុធា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិកអចិន្ត្រៃយ៍ |
| ៣. លោក **ហាក់ លីណា** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិក |
| ៤. លោកស្រី **ឡាយ វីរៈបុត្រ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិក |
| ៥. លោក លោកស្រី | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត | សមាជិកចំពោះកិច្ច |
| ៦. លោក **ឡុច រៀមដែត** | ប្រធានការិយាល័យឥណទានជនបទ | លេខាធិការ |

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

**ប្រការ ២.-** ក្រុមប្រឹក្សាភិបាលនៃគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ មានភារកិច្ចដូចខាងក្រោម÷

- ពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃលទ្ធផលប្រតិបត្តិការឥណទាន និងហិរញ្ញវត្ថុរបស់គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ
- ពិនិត្យ និងអនុម័តលើគម្រោងផែនការប្រចាំឆមាស-ឆ្នាំ (ផែនការសកម្មភាព-ផែនការអាជីវកម្ម ផែនការចំណូល ផែនការថវិកា)
- ផ្តល់យោបល់ណែនាំដល់អង្គភាពគ្រប់គ្រងគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការគ្រប់គ្រងប្រតិបត្តិការគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ តាមផែនការ គោលការណ៍ និងនីតិវិធីឥណទាន
- ពិនិត្យ និងផ្តល់យោបល់កែលម្អគោលការណ៍ និងគោលនយោបាយនៃគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ
- ផ្តល់ប្រឹក្សាលើការរៀបចំផែនការយុទ្ធសាស្ត្រ និងការប្រកួតប្រជែងទីផ្សារ។

**ប្រការ ៣.-** ក្រុមប្រឹក្សាភិបាលនៃគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ធ្វើការប្រជុំសាមញ្ញរបស់ខ្លួនពីរដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន ប៉ុន្តែអាចធ្វើការប្រជុំវិសាមញ្ញយោងតាមតម្រូវការចាំបាច់នៃការងារដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម ÷

- ការប្រជុំអាចយកជាការបាន លុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប) ភាគរយនៃសមាជិកទាំងអស់
- ការអនុម័តត្រូវធ្វើឡើងដោយលើកដៃ និងដោយសំឡេងភាគច្រើននៃសមាជិកដែលបានចូលរួមប្រជុំ ប៉ុន្តែក្នុងករណីសំឡេងស្មើគ្នា សំឡេងអធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាមានឧត្តមានុភាព
- សមាជិកចំពោះកិច្ច អាចចូលរួមពិភាក្សាក្នុងគ្រប់កិច្ចប្រជុំ ប៉ុន្តែអាចចូលរួមអនុម័តបានតែលើគម្រោង ឬករណីដែលពាក់ព័ន្ធនឹងរាជធានី ខេត្តរបស់ខ្លួនប៉ុណ្ណោះ។

**ប្រការ ៤.-** បង្កើតអង្គភាពគ្រប់គ្រងគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ជាស្នាក់ការកណ្តាល នៃគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. បណ្ឌិត **ភាគ សុធា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | ប្រធាន |
| ២. លោក **ហាក់ លីណា** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | អនុប្រធាន |
| ៣. លោកស្រី **ឡាយ វីរៈបុត្រ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | គណនេយ្យករ ហិរញ្ញវត្ថុ |
| ៤. លោក **ឡុច រៀមដែត** | ប្រធានការិយាល័យឥណទានជនបទ | មន្ត្រីឥណទាន |
| ៥. លោក **អាំង ពៅម៉ានិច** | អនុប្រធានការិយាល័យឥណទានជនបទ | គណនេយ្យករ ឥណទាន |
| ៦. លោក **ឌី សារ៉ាត់** | អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | មន្ត្រីរដ្ឋបាល |
| ៧. លោក **ស៊ាន លីហេង** | អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | សវនករផ្ទៃក្នុង |

**ប្រការ ៥.-** អង្គភាពគ្រប់គ្រងគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ទទួលខុសត្រូវក្នុងការគ្រប់គ្រងរាល់ប្រតិបត្តិការរបស់អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ទាំងអស់ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងចីរភាព ដោយផ្អែកលើគោលនយោបាយ នីតិវិធី និងគោលការណ៍ជាធរមានដែលកំណត់ដោយក្រសួងអភិវឌ្ឍន៍ជនបទ។

**ប្រការ ៦.-** អង្គភាពគ្រប់គ្រងគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ មានភារកិច្ចដូចខាងក្រោម÷

- រៀបចំផែនការអាជីវកម្មប្រចាំឆ្នាំរបស់អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលនៃគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ពិនិត្យ និងអនុម័ត
- តាមដានការប្រមូលប្រាក់ដើម និងការប្រាក់មកវិញឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា
- តាមដាន និងត្រួតពិនិត្យការអនុវត្តរបស់អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទប្រចាំរាជធានី ខេត្តទាំងអស់ តាមផែនការ គោលការណ៍ និងនីតិវិធីឥណទាន
- គ្រប់គ្រងហិរញ្ញវត្ថុ ឥណទាន និងសារពើភ័ណ្ឌគម្រោង ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់
- គ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រ និងការប្រកួតប្រជែងទីផ្សារ
- សហប្រតិបត្តិការ សម្របសម្រួល និងស្វែងរកដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងស្ថាប័នផ្សេងៗ ដើម្បីពង្រីកទុនឥណទាន និងតំបន់ប្រតិបត្តិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន។

**ប្រការ ៧.-** រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ប្រធានអង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ រាជធានី ខេត្ត និងសាមីជនដែលរាយនាមក្នុងប្រការ ១ និងប្រការ ៤ មានភារកិច្ចអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ជា សុផារ៉ា

<u>កន្លែងទទួល</u>÷

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ធនាគារជាតិនៃកម្ពុជា
 *"ដើម្បីជូនជ្រាប"*
-ដូចប្រការ ៨
 *"ដើម្បីអនុវត្ត"*
-ឯកសារ-កាលប្បវត្តិ